# ការឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត

VOTE 2018

## អ្នកមានសិទ្ធិក្នុងការឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោតដោយគ្មានការកាត់ប្រាក់បៀវត្សរ៍ ការឈប់ សម្រាប់ផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។

និយោជករបស់អ្នកត្រូវទូទាត់ប្រាក់ជូនអ្នកសម្រាប់ ពេលវេលាដែលអ្នកត្រូវទៅបោះឆ្នោតប្រសិនបើថ្ងៃ បោះឆ្នោតចំម៉ោងការងារធម្មតារបស់អ្នក។ និយោជក របស់អ្នកមិនអាចតម្រូវឱ្យអ្នកប្រើប្រាស់ថ្ងៃឈប់សម្រាកផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។

ចំណាយពេលវេលាដែលអ្នកត្រូវការចាំបាច់ដើម្បីទៅបោះឆ្នោត និងទៅធ្វើការ។

និយោជករបស់អ្នកមិនអាចបដិសេធ ដាក់កំហិត ឬរំខានដល់សិទ្ធិនេះដោយផ្ទាល់ ឬដោយប្រយោល ឡើយ រួមទាំងការជ្រើសរើសពេលវេលារបស់អ្នកដើម្បីទៅបោះឆ្នោតផងដែរ។
និយោជករបស់អ្នកអាចសុំឱ្យអ្នកប្រាប់គាត់អំពីពេលវេលាដែលអ្នកត្រូវទៅ និងសុំឱ្យបុគ្គលិកជួយសម្រប សម្រួលអវត្តមានរបស់ខ្លួនដើម្បីកាត់បន្ថយការអាក់ខាន នៅកន្លែងធ្វើការ។

អ្នកមានសិទ្ធិឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោតនៅក្នុងគ្រប់ការបោះឆ្នោតប្រចាំរដ្ឋ និងសហព័ន្ធ និងនៅក្នុងគ្រប់ការបោះឆ្នោតក្នុងមូលដ្ឋានដែលបានកំណត់
ពេលជាទៀងទាត់។

### កាលបរិច្ឆេទឆ្នាំ 2018

**ការបោះឆ្នោតបឋម**
ថ្ងៃអង្គារ៍ទី14 ខែសីហា

**ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន**
បោះឆ្នោតតាមសំបុត្រ ឬដោយផ្ទាល់ថ្ងៃទី21 ខែកញ្ញា រហូតដល់ថ្ងៃទី5 ខែវិច្ឆិកា

**ចុះឈ្មោះបោះឆ្នោត**ចុះឈ្មោះជាមុននៅត្រឹមថ្ងៃទី16 ខែតុលា ដើម្បីសន្សំសំចៃពេលវេលានៅថ្ងៃបោះឆ្នោត។

**ថ្ងៃបោះឆ្នោត**
ថ្ងៃអង្គារ៍ទី6 ខែវិច្ឆិកា

តទៅទំព័រក្រោយ...

**ការិយាល័យលេខាធិការរដ្ឋ Minnesota**
*mnvotes.org • 1-877-600-VOTE*

# ការឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត

VOTE 2018

.... តពីទំព័រមុខ

## ការដាក់ពាក្យប្តឹង

និយោជកដែលរំលោភទៅលើច្បាប់នេះគឺមានបទល្មើសមជ្ឈិម។ រាល់បណ្តឹងពីបុគ្គលិកគួរដាក់ប្តឹងទៅមេធាវី ប្រចាំក្រុង។

## បោះឆ្នោតមុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន

អ្នកអាចបោះឆ្នោតមុនពេលកំណត់ប្រសិនបើអ្នកមិន ចង់ទៅ ឬមិនអាចបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ ដោយ ចាប់ផ្តើមពីថ្ងៃសុក្រទី21 ខែកញ្ញា អាចបោះឆ្នោត មុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាននៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់ អ្នក។ អ្នកក៏អាចដាក់ពាក្យស្នើសុំឱ្យបញ្ជូនសន្លឹកឆ្នោត សម្រាប់ពលរដ្ឋអវត្តមានតាមលិខិតផងដែរ។

ដើម្បីស្វែងរកការិយាល័យបោះឆ្នោតក្នុង មូលដ្ឋានរបស់អ្នក ឬដើម្បីស្នើសុំសន្លឹកឆ្នោតសម្រាប់ ពលរដ្ឋអវត្តមាន សូមចូលទៅកាន់វេបសាយត៍ mnvotes.org។

### លិខិតសម្រាប់និយោជករបស់អ្នក

សូមចូលទៅកាន់វេបសាយត៍ *mnvotes.org* ដើម្បី ស្វែងរកលិខិតដែលអ្នកអាចផ្តល់ជូននិយោជករបស់អ្នក ដើម្បីពន្យល់អំពីសិទ្ធិរបស់អ្នកក្នុងការឈប់សម្រាក ដើម្បីទៅបោះឆ្នោត។

**ការិយាល័យលេខាធិការរដ្ឋ** *Minnesota*
*mnvotes.org • 1-877-600-VOTE*